## សាវតារសង្ខេប

- កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(កម្មវិធីRIA) នៅកម្ពុជាសំដៅពង្រឹងភាពប្រកួតប្រជែងនិងប្រសិទ្ធភាពនៃបញ្ញត្តិកម្ម តាមរយៈការដាក់ឲ្យអនុវត្តនូវគោលការណ៍ប្រតិបត្តិល្អក្នុងនីតិវិធីរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តនៅតាមក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល។ ប្រព័ន្ធនៃការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(ប្រព័ន្ធRIA)តម្រូវឲ្យក្រសួងនីមួយៗអនុវត្តតាមគោលការណ៍ប្រតិបត្តិល្អ និងវាយតម្លៃលើស្មារតីឬខ្លឹមសារនៃបទប្បញ្ញត្តិដែលមានផលប៉ះពាល់ដល់បន្ទុកចំណាយនិងការប្រកួតប្រជែងរបស់ធុរកិច្ច។
- ឆ្នាំ២០០៨: វិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(វិធីសាស្ត្រRIA) ត្រូវបានអនុវត្តសាកល្បងនៅអតីតក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ស្ថិតនៅក្រោមកម្មវិធីលើកកម្ពស់គុណភាពលិខិតបទដ្ឋានគតិយុត្ត ដែលគាំទ្រដោយជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)។




**សម្តេចវិបុលបញ្ញា សុខ អាន ពិធីចុះMoUជាមួយADB បង្កើតគម្រោងRIA ឆ្នាំ២០១០**

- ឆ្នាំ២០១១–២០១៥: គម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(គម្រោងRIA) (ជំនួយ ADB លេខ 0224) ត្រូវបានអនុវត្តដោយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ (ក្នុងនាមជាទីភ្នាក់ងារប្រតិបត្តិគម្រោង) ដែលមានការចូលរួមអនុវត្តពីក្រសួងចំនួន ៧ (ក្នុងនាមទីភ្នាក់ងារអនុវត្តគម្រោង)។
- នៅឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ១៣២ សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដូច្នេះក្រសួងស្ថាប័នបានចូលរួមកាន់តែច្រើន ដែលមកដល់បច្ចុប្បន្ននេះមានក្រសួងចំនួន១៦ ព្រមទាំងស្ថាប័នចំនួន២៖ ក្រសួងរ៉ែនិងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងសុខាភិបាល ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ។ កម្មវិធីRIAនេះបន្តដឹកនាំដោយក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តក្រោមការដឹកនាំពី ឯកឧត្តមទេសរដ្ឋមន្ត្រី យឹម ណុលឡា ឯកឧត្តម យឹម ណុលសន និងការគ្រប់គ្រងដោយ ឯកឧត្តម ប៉ិច សុខា។ ធនាគារអភិវឌ្ឍន៍អាស៊ី បានបន្តជួយឧបត្ថម្ភជំនួយបច្ចេកទេស (TA) រហូតដល់ខែមិថុនា ឆ្នាំ២០១៩។




**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាអធិបតីភាពក្នុងពិធីបិទសិក្ខាសាលាអន្តរជាតិថ្នាក់តំបន់ស្តីពីRIA នៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧**

# ការបង្កើតក្រុមការងារ






តំណាងក្រុមការងារRIAរបស់ក្រសួងស្ថាប័នទាំង១៩

## លទ្ធផលសម្រេចបាន

**លទ្ធផលទី១** - កសាងធនធានមនុស្ស: ពីឆ្នាំ២០១១ដល់ ខែធ្នូ ឆ្នាំ២០១៨ បានបណ្តុះបណ្តាលមន្ត្រី ចំនួន ១២៩៨នាក់ (រួម ដំណើរសិក្សាដកពិសោធន៍នៅប្រទេសអូស្ត្រាលី អង់គ្លេស វៀតណាម កាណាដា ផងដែរ។



ឯកឧត្តម យឹម ណុលសន អនុប្រធាន ECOSOCC បើកវគ្គបណ្តុះបណ្តាល នៅក្រសួងរ៉ែ និងថាមពល នៅខែមិថុនា ឆ្នាំ២០១៨




ឯកឧត្តម ប៉ិច សុខាអគ្គលេខាធិការរងECOSOCC បើកវគ្គបណ្តុះបណ្តាលនៅសាលាមភមិន្ទរដ្ឋបាល នៅខែកុម្ភៈ ឆ្នាំ២០១៧

**លទ្ធផលទី២** - របាយការណ៍RIA: ពីឆ្នាំ២០១១ដល់ខែធ្នូឆ្នាំ២០១៨ ក្រសួងស្ថាប័នបានបញ្ចប់របាយការណ៍វាយតម្លៃបឋម ចំនួន៥៣ និងរបាយការណ៍វាយតម្លៃពេញលេញចំនួន៣ ហើយកំពុងរៀបចំរបាយការណ៍វាយតម្លៃបឋមចំនួន៩ទៀត។

**លទ្ធផលទី៣** - ការផ្សព្វផ្សាយអំពីRIA: ពីឆ្នាំ២០១១ដល់ខែធ្នូឆ្នាំ២០១៨ បានធ្វើការផ្សព្វផ្សាយជាសាធារណៈដល់ក្រសួង ស្ថាប័ន វិស័យឯកជន គ្រឹះស្ថានឧត្តមសិក្សា សង្គមស៊ីវិល ចំនួន២២១ដង និងមានអ្នកចូលរួមសរុបចំនួន ១១,៩៨០នាក់។




ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ប្រធានECOSOCC ជាអធិបតីភាពក្នុងពិធីបើកសិក្ខាសាលាអន្តរជាតិថ្នាក់តំបន់ស្តីពីRIA
នៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧







## ផែនទីបង្ហាញផ្លូវនៃការអនុវត្តកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

| ដំណាក់កាលទី១ (២០០៨-២០១៥) | ដំណាក់កាលទី២ (២០១៦-២០១៧) | ដំណាក់កាលទី៣ (២០១៨-២០១៩) |
|---|---|---|
| - សាកល្បងអនុវត្តRIA ដំបូងជាមួយក្រសួងមួយ រួចជាមួយក្រសួងចំនួន៤ ហើយបន្តជាមួយក្រសួងចំនួន៧ ទៀត<br>- បានបង្ហាញថាការអនុវត្តRIAមានអត្ថប្រយោជន៍ដល់ការរៀបចំលិខិតបទដ្ឋានគតិយុត្តឲ្យមានប្រសិទ្ធភាព<br>- ផ្សព្វផ្សាយអំពីRIA | - បន្តការបណ្តុះបណ្តាលមន្ត្រីក្នុងការអនុវត្តRIAនៅតាមក្រសួង ស្ថាប័ន ដែលចូលរួមក្នុងកម្មវិធីRIA (ចំនួន ១៨)<br>- បន្តផ្សព្វផ្សាយអំពីRIA<br>- រៀបចំកែសម្រួលការអនុវត្តRIAទៅតាមលក្ខណប្បញ្ញត្តិប្រទេសកម្ពុជា<br>- ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌បន្តគ្រប់គ្រងកម្មវិធីRIA | - អនុវត្តRIA ឲ្យបានទូលំទូលាយនៅតាមក្រសួងចំនួន១៦ ដែលបានចូលរួម ក្នុងកម្មវិធីRIA<br>- វាយតម្លៃអំពីវឌ្ឍនភាព និងកែសម្រួល ដើម្បីអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាពទៅតាមបរិបទកម្ពុជា |